# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញក្រឹត្យលេខ ៥៧ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៦ ។

## ស ម្រេ ច

**មាត្រា ១.–**

អនុក្រឹត្យនេះ មានគោលបំណងកំណត់យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល ។

**មាត្រា ២.–**

យថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ មានដូចខាងក្រោម :

ក- ផល អនុផលព្រៃឈើកែច្នៃ ឬមិនកែច្នៃគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមពីប្រភពព្រៃដាំ។ ឈើដើមកៅស៊ូ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

ខ- ផល អនុផលព្រៃឈើដែលប្រើប្រាស់វត្ថុធាតុដើមស្របច្បាប់ពីប្រភពព្រៃធម្មជាតិដូចខាងក្រោម :

១- គ្រឿងសង្ហារឹម គ្រឿងផ្គុំសម្រាប់សង្ហារឹម និងគ្រឿងផ្គុំទូឯកសារ

២- ឈើគ្រឿងចម្លាក់ ឧបករណ៍ក្មេងលេង គ្រឿងតុបតែងលំអ គ្រឿងអនុស្សាវរីយ៍ គ្រឿងប្រដាប់ប្រដាការិយាល័យផលិតពីឈើ ឬអនុផលព្រៃឈើគ្រប់ប្រភេទ និងផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

៣- ឈើប៉ាកេ និងឈើការ៉ូក្រាល

៤- ឈើប៉ាឡែត និងឈើធ្វើឡាំង ( ផ្គុំរួច ឬមិនទាន់ផ្គុំ)

៥- ឈើលាក់ ឬលកញីឈ្មោល ឈើក្រឡឹង និងខាត់ គ្រោងទ្វារ-បង្អួច ឈើមានដំណាប់ ឬពន្លួញញីឈ្មោល ( ឈើធ្វើដងឧបករណ៍ប្រើប្រាស់)

៦- ផលិតផលឈើបិទការ៉ជាបន្ទះ ឬជាចំណិតភ្ជាប់គ្នា

៧- ក្តារធ្វើពីកំទេចឈើក្រោមសម្ពាធខ្លាំង និងក្តារបន្ទះ ( កុងប្លាកេ)

៨- ឈើរនៀវ ឈើចិត ឈើចៀរជាសន្លឹក

៩- ឈើអារតាមខ្នាត់ទទឹងសាច់ឈើដែលមានកម្រាស់អតិបរមា១៥ស.ម ទោះបីនៅជាប់សំបកក៏ដោយ

១០- ឈើឈូសមុខ ២ ឬមុខ ៤ ព្រមទាំងមានខ្នាត និងគុណភាពនាំចេញ

១១- ចំណាំងកំទេចឈើ ម្សៅឈើ

១២- ឈើគូស ឈើចាក់ធ្មេញ ចង្កឹះ

១៣- ឈើកំណល់ផ្លូវរថភ្លើង ( លើកលែងឈើប្រណិត)

១៤- ឈើជ្រុងដែលមានទោល ឬបន្ទារអតិបរមា ២៥ ស.ម ដែលបានសម្ងួតតាមលក្ខណៈធម្មជាតិ ឬក្នុងឡសម្ងួតតាមលក្ខណៈបច្ចេកទេស

១៥- ស៊ុមរូបវិចិត្រ ស៊ុមរូបថត ស៊ុមកញ្ចក់ ផ្ទាំងប្រជីស ជើងទម្រផ្ទាំងប្រជីស និងផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

១៦-ផល អនុផលព្រៃឈើកែច្នៃមានលក្ខណៈប្រពៃណីរួមមាន :

ក- ផលិតផលមានចរិតសិល្បៈប្រពៃណីជាតិដូចជា ទូក ង ទូក មួង រទេះគោ រទេះក្របី រទេះសេះ រយាងដីរ

ខ-ឧបករណ៍ប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃដូចជា ស្នា ធ្នូ ត្បាល់ អង្រែ សង្រែក ជាល ល្អី ចង្អេរ កញ្ច្រែង កញ្ជើរ ហឹប ឈ្នាង ទ្រុងសត្វ ប្រអប់ដាក់គ្រឿងលោហៈធាតុ ប្រអប់ស្លា ម្លូ បារី គ្រឿងបណ្ណាការ ផលិតផលតម្បាញរុក្ខជាតិ ឈើច្រត់ ដំបងមូល ដំបងជ្រុង

គ-ឧបករណ៍ និងមធ្យោបាយបម្រើឱ្យផលិតកម្មកសិកម្មដូចជា នង្គ័ល រនាស់ ដងចប ដងកាំបិត ដងពូថៅ ស្ទឹង ស្នៀត បង្គី

ឃ-ឧបករណ៍ និងមធ្យោបាយបម្រើឱ្យផលិតកម្មនេសាទដូចជា អង្រុត ឈ្នាង លប ទ្រូ បង្គោល ដងច្បូក ច្រវ៉ា ចែវ

ង- ឧបករណ៍តន្ត្រីដូចជា ស្គរ តាខេ រនាត ទ្រ ចាប៉ី ឃឹម

ច- ផលិតផល ដែលមានលក្ខណៈស្រដៀងគ្នា។

១៧- ក្តារបន្ទះឫស្សី គ្រឿងផ្គុំឫស្សី ផ្តៅ វល្លិ៍ និង ផលិតផលដែលមានលក្ខណៈស្រដៀងគ្នា

១៨- ជ័រឈើ និង ផ្សិតព្រៃគ្រប់ប្រភេទ

១៩- ប្រេងចម្រាញ់ចេញពីផល អនុផលព្រៃឈើ

២០- ផលិតផលពីរុក្ខជាតិឱសថ ផលិតផលពីរុក្ខជាតិពុល ផលិតផលពីរុក្ខជាតិក្រអូប រុក្ខជាតិមានសារធាតុគីមីជីវៈ សារធាតុសម្លាប់ស្បែក

២១- ផលិតផលផ្កា ស្លឹក ផ្លែ រុក្ខជាតិព្រៃ

២២- ផល និងផលិតផលកែច្នៃពីអនុផលព្រៃឈើគ្រប់ប្រភេទ

២៣- ផលិតផលសត្វព្រៃកែច្នៃ ឬមិនកែច្នៃ និងសំណាកសត្វព្រៃក្នុងក្រុមប្រភេទមានដោយបង្គួរ។

**មាត្រា ៣.–**

យថាប្រភេទផល អនុផលព្រៃឈើ ដែលហាមនាំចេញមានដូចខាងក្រោម :

១- ឈើហ៊ុប ទោះបីបកសំបក ឬទាំងសំបក

២- ឈើអារសុទ្ធសាច

៣- ឈើជ្រុង ដែលមានកម្រាស់លើសពី ២៥ ស.ម ទោះបីបានឈូសហើយក៏ដោយ

៤- ប្រេងម្រះព្រៅ វល្លិ៍រមៀត និងម្សៅវល្លិ៍រមៀត

៥- អុស និងធ្យូងឈើ ដែលមានប្រភពពីព្រៃធម្មជាតិ ។

**មាត្រា ៤.–**

យថាប្រភេទផល អនុផលព្រៃឈើ ដែលអនុញ្ញាតឱ្យនាំចូលមានដូចខាងក្រោម :

ក- ឈើហ៊ុបមូល ឈើហ៊ុបជ្រុង ឈើអារ និង ផល អនុផលព្រៃឈើដទៃទៀត ។

ខ- ផល អនុផលព្រៃឈើកែច្នៃ ។

**មាត្រា ៥.–**

ផល អនុផលព្រៃឈើដែលអនុញ្ញាតឱ្យនាំចេញ នាំចូល ត្រូវបង់ពន្ធជូនរដ្ឋតាមច្បាប់កំណត់ ។

**មាត្រា ៦.–**

ដូចមានចែងក្នុងមាត្រា ២ ចំណុច ខ វាក្យខ័ណ្ឌទី ១៦ នៃអនុក្រឹត្យនេះ :

ក-ការនាំចេញជាលក្ខណៈគ្រួសារ ឬទេសចរណ៍នូវផល អនុផលព្រៃឈើកែច្នៃ ដែលមានលក្ខណៈប្រពៃណី ពុំតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ និងលិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើឡើយ ។

ខ-ការនាំចេញរបស់អតិថិជន ឬភាគីទិញនូវផល អនុផលព្រៃឈើកែច្នៃដែលមានលក្ខណៈប្រពៃណី ក្នុងគោលដៅពាណិជ្ជកម្ម ពុំតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញឡើយ ប៉ុន្តែតម្រូវឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើ ។

**មាត្រា ៧.–**

ការនាំចេញផល អនុផលព្រៃឈើដូចមានចែងក្នុងមាត្រា ២ ចាំបាច់ត្រូវមានអាជ្ញាប័ណ្ណនាំចេញ ដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន លើកលែងតែផលិតផល ដែលមានចែងក្នុងមាត្រា ២ ចំណុច ខ វាក្យខ័ណ្ឌទី ១៦ នៃអនុក្រឹត្យនេះ ។ ការពន្យារសុពលភាពនៃអាជ្ញាប័ណ្ណនាំចេញនេះ ត្រូវផ្តល់ដោយក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៨.–**

ការនាំចូលផល អនុផលព្រៃឈើ ដែលប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ផលិតកម្មកែច្នៃក្នុងប្រទេស និង ផល អនុផលព្រៃឈើកែច្នៃគ្រប់ប្រភេទ ដែលបានកំណត់ក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ តម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចូលដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម និងមានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើជាមុន និងមានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូល ដែលចេញដោយប្រធានរដ្ឋបាលព្រៃឈើ ។

**មាត្រា ៩.–**

ហាមដាច់ខាតការនាំចូលនូវប្រភេទរុក្ខជាតិព្រៃ ឬសត្វព្រៃដែលជាប្រភេទរាតត្បាត ឬធ្វើឱ្យប៉ះពាល់ដល់ធនធានសេនេទិចប្រភពកំណើត ។

**មាត្រា ១០.–**

អាស្រ័យតាមការចាំបាច់នៃតម្រូវការពាណិជ្ជកម្មក្នុងតំបន់ ឬអន្តរជាតិ ឬតាមតម្រូវការនៃសង្គម សេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលអាចអនុញ្ញាតឱ្យនាំចេញ នាំចូលនូវផល អនុផលព្រៃឈើដទៃទៀតបាន ។

**មាត្រា ១១.–**

យថាប្រភេទផល អនុផលព្រៃឈើ អាចអនុញ្ញាតឱ្យនាំចេញ នាំចូលបានតាមមាត់ច្រកទ្វារព្រំដែនស្របច្បាប់ ។

**មាត្រា ១២.–**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-សាលាខេត្ត-ក្រុង
-សភាពាណិជ្ជកម្ម
-ដូចមាត្រា ១៣
-ឯកសារ-កាលប្បវត្តិ